ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

កុម្ភៈ ២០០៥ / February 2005

កញ្ញា អ៊ុច ចំន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**

លោក តុង គីមស៊ុន / **Mr. Tong Kim Sun**

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

យោងតាម CDC វិនិយោគឯកជនគិតជាទ្រព្យសកម្មជាប់លាប់ដែលបានអនុម័តសំរាប់វិស័យកាត់ដេរ មាន ១១០,១លានដុល្លារនៅឆ្នាំ២០០៤ (គិតដល់ចុងខែវិច្ឆិកា) ឬកំណើន ៧៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ប្រទេសវិនិយោគិន ៣ ចំបងគេ គឺមាន ចិន តៃវ៉ាន់ និងអង់គ្លេស ។

According to the CDC, approvals of private investment in fixed assets in the garment sector amounted to $110.1 million in 2004 (to the end of November), a rise of 79 percent compared to the same period in 2003. Of the total, foreign direct investment accounted for 74 percent in 2004 (up to November), compared to only 38 percent in the same period of 2003, an increase from $23 million to $82 million. The top three foreign investors during the first 11 months of 2004 were China, Taiwan and the United Kingdom. Domestic investment, however, declined by about 26 percent, to $28.5 million.

**Garment Sector Fixed Asset Investments Approved by CDC**
(millions of dollars)




*Note: The latest data available are for November 2004.*
*(Including expansion projects.)*
Source: Council for the Development of Cambodia

នៅឆ្នាំ២០០៤ (គិតដល់ចុងខែវិច្ឆិកា) ភ្ញៀវបរទេសចូលមកកម្ពុជាតាមយន្តហោះ មានសរុប ៥៤៨.៤៩២នាក់ ឬ ៣៨% ច្រើនជាងរយៈពេលដូចគ្នាឆ្នាំមុន ។ ភ្ញៀវចូលតាមអាកាសយានដ្ឋានអន្តរជាតិសៀមរាប កើន ៧០% ដល់ ២៦៧.៥២៤នាក់ ។ ដោយឡែកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញទទួលភ្ញៀវចូល ២៨០.៩៦៨នាក់ (កំណើន ១៧%) ។

In 2004 (to the end of November), the total of foreign visitors to Cambodia by air amounted to 548,492 persons, 38 percent more than in the same period of 2003. Visitors arriving at Siem Reap international airport rose by 70 percent, to 267,524 persons. In addition, Phnom Penh international airport received 280,968 persons, a 17 percent increase.

**Number of Arrivals on International Flights**
(thousands)




** To end of November.*
Source: Ministry of Tourism

ពីខែមករា-វិច្ឆិកា ២០០៤ ក្រុងភ្នំពេញបានអនុម័ត ៨៥៣គំរោងសាងសង់ (កំនើន ៣៥%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន) ក្នុងនេះមាន ៥៨២គំរោងសាងសង់ផ្ទះល្វែង (កើន ៣២%ខ្ពស់ជាងឆ្នាំ២០០៣), ១៧៤គំរោងភូមិគ្រឹះ (កើន ៤៧,៥%) និង ៩៧គំរោងសំណង់ផ្សេងៗ (កើន ៣៣%) ។ ពីខែមករា ដល់ចុងខែវិច្ឆិកា ២០០៤ គំរោងសាងសង់បានអនុម័តឡើងដល់ប្រហែល ២៣០,៧លានដុល្លារ ឬ ១៦%ច្រើនជាងឆ្នាំ២០០៣ ។

In the period January–November 2004, the municipality of Phnom Penh approved 853 construction projects, an increase of 35 percent over the same period in 2003. Apartment construction projects made up about 70 percent of the total approvals, rising by 32 percent to 582 projects. Houses and others construction activities increased by 47.5 percent, to 174 projects, and 33 percent, to 97 projects, respectively. Construction approvals reached an estimated amount of $230.7 million in 2004 (to the end of November), 16 percent more than in 2003.

**Applications for Construction Projects in Phnom Penh**




** To end of November.*
Source: Department of Cadastre and Geography of the municipality of Phnom Penh

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

តាំងពីខែវិច្ឆិកា ២០០៤ ថ្លៃសាំងនៅ ៣តំបន់ខុសៗគ្នា (ភ្នំពេញ, សៀមរាប, បាត់ដំបង) មានស្ថិរភាពល្អ ។ នៅភ្នំពេញ និងសៀមរាប សាំងមានថ្លៃ ៣.០៥០រៀល/លីត្រ ឯនៅបាត់ដំបង ថ្លៃ ៣.០០០រៀល/លីត្រ ។

Since November 2004, the gasoline price in the three different areas (Phnom Penh, Siem Reap and Battambang) has remained stable. In Phnom Penh and Siem Reap, the price was 3,050 riels/litre, while it was 3,000 riels/litre in Battambang.

**Price of Gasoline in Battambang, Siem Reap and Phnom Penh (riels/litre)**




Sources: CDRI and National Institute of Statistics

គិតពីមួយខែទៅមួយខែ ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញថយចុះ ០,២% នៅខែធ្នូ ២០០៤ ធៀបនឹងការថយចុះ ០,៤% នៅខែមុន ។ ការថយចុះយឺតជាងមុននេះ បណ្ដាលជាសំខាន់ពី កំនើនថ្លៃផលិតផលមួយចំនួន (ភាគច្រើនទំនិញនាំចូលពីថៃ) ដូចជា សំភារៈសំរាប់ប្រើប្រាស់ក្នុងផ្ទះ, សំភារៈសិក្សា និងគ្រឿងសំអាងកាយ ។

On a month-to-month basis, consumer prices in Phnom Penh declined by 0.2 percent in December 2004, compared with 0.4 percent in the preceding month. The slower decline was mainly caused by an increase in prices of some products, mostly imports from Thailand, such as materials for household operation, school supplies and personal care products.

**Consumer Price Index**

(July–December 2000 = 100)




Source: National Institute of Statistics

នៅខែវិច្ឆិកា អង្កេតពលករងាយរងគ្រោះធ្វើនៅភ្នំពេញ ដោយ វបសអ បានបង្ហាញពីការធ្លាក់ចុះប្រាក់ចំនូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូ (ធ្លាក់ ៣៧%), កម្មករសំណង់មានជំនាញ (ធ្លាក់ ២២%), អ្នកលីសែង (ធ្លាក់ ១៤%), និងអ្នករត់ម៉ូតូឌុប (៥%) បើធៀបនឹងខែវិច្ឆិកា ២០០៣ ។ ផ្ទុយទៅវិញ អ្នកស៊ីឈ្នួលធ្វើស្រែ កើនចំណូល (ប្រហែល ១៣%) ឯប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មកររោងចក្រកាត់ដេរ សឹងតែគ្មានការប្រែប្រួលនៅត្រឹម ១០.០០០រៀល/ថ្ងៃ ។

In November, the vulnerable workers survey in Phnom Penh conducted by CDRI showed that there was a decline in the average daily income of cyclo drivers (by 37 percent), skilled construction workers (22 percent), porters (14 percent) and moto taxi driver (5 percent), compared to November 2003. Conversely, scavengers earned more (about 13 percent), while the daily income of garment workers remained almost unchanged at 10,000 riels/day.

**Average Daily Income and Spending (food only) of Vulnerable Workers in Phnom Penh**

(November 2004, US$)




Source: CDRI

# ស្ថានភាពអត្រាប្តូរប្រាក់និងរូបិយវត្ថុ
# Exchange Rate and Monetary Developments

នៅខែមករា ២០០៥ ប្រាក់រៀលបានចុះថ្លៃទល់នឹងដុល្លារ (បន្ទាប់ពីបានឡើងថ្លៃអស់៣ខែជាប់ៗគ្នា) ដោយប្តូរបាន ៤.០៣៩រៀល/ដុល្លារ ឬចុះថ្លៃ ០.២% ពីកំរិត ៤.០៣០រៀល/ដុល្លារកាលពីខែធ្នូ ២០០៤ ។

In January 2005, the riel fell against the US dollar, after appreciating for three consecutive months. Compared to December, the riel depreciated by 0.2 percent, from 4,030 riels/dollar to 4,039 riels/dollar in January 2005.

**Riels per US Dollar**
(market and official rates)




Source: National Bank of Cambodia and CDRI

នៅខែមករា ២០០៥ ប្រាក់រៀលចុះថ្លៃអស់ ៥ខែជាប់ៗគ្នាទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១០៤រៀល/បាត ឬចុះថ្លៃ ១.៦% ធៀបនឹងខែធ្នូ ២០០៤ ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលមានស្ថិរភាពនៅត្រឹម ២៥.៥រៀល/១០០ដុង នៅខែមករា នេះ គឺដូចគ្នានឹងកាលពីខែមុន ។

The riel depreciated against the Thai baht for the fifth consecutive month in January, trading at 104 riels/baht, a depreciation of 1.6 percent from December 2004. Against the Vietnamese dong, on the other hand, the riel remained steady at 25.5 riels per 100 dongs in January, the same as in the preceding month.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI and the Economist

យោងតាមទិន្នន័យអង្កេតរូបិយវត្ថុប្រចាំខែរបស់ ធនាគារជាតិនៃកម្ពុជា រូបិយវត្ថុទូទៅ (M2) បានថយចុះនៅខែវិច្ឆិកា ២០០៣ ដែលជាលើកទី១ ហើយ គិតតាំងពីខែសីហា ២០០៣ មក ។ ពីខែតុលា-វិច្ឆិកា រូបិយវត្ថុទូទៅ ថយចុះបន្តិចត្រឹម ០.៤% ដល់ ៤.២៩០.៣ពាន់លានរៀល ដែលឆ្លុះបញ្ចាំងពីការថយចុះប្រាក់បញ្ញើជារូបិយវត្ថុបរទេសអស់ ០.៦% ពី ៧៧៣.៨លានដុល្លារ ដល់ ៧៦៩.២លានដុល្លារ ។ ប៉ុន្តែចំណែកជាប្រាក់រៀលកើន ២% ដល់ ១.១៧២.២ពាន់លានរៀល ដោយសារការបញ្ចេញក្រដាសប្រាក់បន្ថែម ។

Based on provisional data from the NBC's monthly monetary survey, total liquidity (M2) declined in November 2004, for the first time since August 2003. Over October-November, liquidity fell marginally, by 0.4 percent, to 4,290.3 billion riels. This reflected a decrease in foreign currency deposits of 0.6 percent, from $773.8 million to $769.2 million. However, the riel component increased by 2 percent, to 1,172.2 billion riels, mainly as a result of a rise of 2.2 percent in currency issued by the NBC.

**Liquidity through the Banking System**
(in billion riels)




*Note: The latest data available are for November 2004 (provisional data).*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

ការនាំចេញផលិតផលកសិកម្មចំបងៗរបស់កម្ពុជាមានសរុប ៥៤,៦លានដុល្លារ នៅឆ្នាំ២00៤ (គិតដល់ចុងខែវិច្ឆិកា) ដែលស្មើនឹង ៣% នៃការនាំចេញសរុប ប៉ុណ្ណោះ ប៉ុន្តែវាកើន ២៦,៥% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ កំណើននេះនាំមុខដោយកំណើន ការនាំចេញត្រី (ពី ២,៥លានដុល្លារដល់ ៩លានដុល្លារ), និងអង្ករ (ពី 0,៥លានដុល្លារ ដល់ ១,៦លានដុល្លារ) ។ កៅស៊ូមានចំណែកធំជាងគេក្នុងការនាំចេញ (កើនពី ៣១លានដុល្លារ ដល់ ៣៤លាន) ហើយការនាំចេញឈើ កើន ១0% ដល់ ១0លានដុល្លារ ។

Cambodia's exports of main agricultural products totalled $54.6 million in 2004 (to the end of November), only 3 percent of total exports. Compared to the same period of 2003, exports of agricultural products rose by 26.5 percent, led by an increase in exports of fish (from $2.5 million to $9 million) and rice (from $0.5 million to $1.6 million). Exports of rubber, which have been the largest portion of agricultural product exports since 2001, rose from $31 million to $34 million. At the same time, wood exports increased by 10 percent to $10 million.

**Exports of Main Agricultural Products**

(in millions of dollars)




**The latest data available are for November 2004.*

Source: Customs and Excise Department

យោងតាមទីចាត់ការគយនិងរដ្ឋាករ ក្នុង ១១ខែដើមឆ្នាំ២00៤ កម្ពុជានាំចូលស៊ីម៉ង់ ៨៧៦.៩៧៦តោន និង ដែក ៧៣.0២៥តោន ។ ម្យ៉ាងទៀត ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២00៣ ការនាំចូលស៊ីម៉ង់ដែលមានកំណើន ៤% បានកើនឡើងយឺតជាង ដែកដែលមានកំណើន ២៨% ។

According to the Customs and Excise Department, Cambodia imported 876,976 tonnes of cement and 73,025 tonnes of steel during the first 11 month of 2004. Cement imports rose by 4 percent, more slowly than steel, which rose by 28 percent, compared to the same period of 2003.

**Imports of Construction Materials**

(thousand tonnes)




* The latest data available are for November 2004.

*(Figures exclude public sector imports.)*

*Source: Customs and Excise Department*

នៅឆ្នាំ២00៤ (គិតដល់ចុងខែវិច្ឆិកា) ការនាំចូលប្រេងម៉ាស៊ូតឡើងដល់ ៣៨៧.៨៨៣តោន ឬ ៥,២% ច្រើនជាងរយៈពេលដូចគ្នាឆ្នាំ២00៣ ។ ផ្ទុយទៅវិញ ការនាំចូលប្រេងសាំងមានចំនួន ៨៥.២១៤តោន ឬ ៩,៨% តិចជាងរយៈពេលដូចគ្នាឆ្នាំ២00៣ និង ប្រហែល ៥% តិចជាងការនាំចូលម៉ាស៊ូត ។

In 2004 (to the end of November), the import of diesel reached 387,883 tonnes, 5.2 percent more than in the same period of 2003. In contrast, the import of gasoline amounted to 85,214 tonnes, 9.8 percent less than in the same period of 2003 and about 5 percent less than diesel imports.

**Imports of Petroleum Products**

(thousand tonnes)




** The latest data available are for November 2004.*

*(Figures exclude public sector imports.)*

Source: Customs and Excise Department

# ប្រភពនិងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

យោងតាម CDC ដៃគូអភិវឌ្ឍន៍បរទេសរបស់កម្ពុជា បានបើកផ្តល់ប្រាក់សរុប ៥,២ពាន់លានដុល្លារ សំរាប់ទ្រទ្រង់ដល់កម្មវិធីអភិវឌ្ឍន៍ផ្សេងៗរបស់កម្ពុជា ពីឆ្នាំ១៩៩២-២០០៣, ឬ ៧៤,៤% នៃតួលេខបានសន្យា ដែលគ្មានបូកចូលឆ្នាំ១៩៩៨ និង ២០០៣ ទេ (ជាឆ្នាំដែលមិនបានធ្វើការប្រជុំក្រុមពិគ្រោះយោបល់) ។ នៅឆ្នាំ២០០៣ មានការបើកផ្តល់ ៥៤៥,៨លានដុល្លារ ដែលជាតួលេខខ្ពស់បំផុតមិនធ្លាប់មាន ។

According to the CDC, external development partners of Cambodia disbursed a total of $5.2 billion to support its development programmes in 1992–2003, 74.4 percent of the pledges, not including 1998 and 2003 (when CG meetings were not held). In 2003, $545.8 million was disbursed, the highest amount in any year.

**External Development Assistance Disbursements by Year: 1992-2003**
(millions of dollars)




** Provisional data for 2003.*
Source: Council for the Development of Cambodia

ពីឆ្នាំ១៩៩២-២០០៣មានការបើកផ្តល់ជំនួយឥតសំណង ៤,១ពាន់លានដុល្លារ ដែលស្មើនឹង ៧៩% នៃការបើកផ្តល់ជំនួយសរុបចំនួន ៥,២ពាន់លានដុល្លារ ។ ក្នុងនេះ ០,៥ពាន់លានដុល្លារបានផ្តល់ឱ្យសំរាប់ឆ្នាំ១៩៩២-១៩៩៣, ១,៨៤ ពាន់លានដុល្លារសំរាប់ឆ្នាំ១៩៩៤-១៩៩៨, និង ១,៨ពាន់លានដុល្លារសំរាប់ឆ្នាំ ១៩៩៩-២០០៣ ។ ការបើកផ្តល់កំចីមាន ១,១ពាន់លានដុល្លារ ក្នុងនេះការបើកផ្តល់នៅឆ្នាំ១៩៩៩-២០០៣ មាន ០,៦ពាន់លានដុល្លារ ឬ ៧៤%ច្រើនជាងក្នុងឆ្នាំ១៩៩៤-១៩៩៨ ។

During 1992-2003, a total of $4.1 billion was disbursed in grants, 79 percent of total disbursements, which were $5.2 billion. Of this, $0.5 billion was granted for 1992–1993, $1.84 billion for 1994–1998, and $1.8 billion for 1999–2003. In addition, disbursements as loans accounted for $1.1 billion. Over the period 1999–2003, loan disbursements amounted to $0.6 billion, 74 percent more than during 1994–1998.

**External Development Assistance Disbursements by Terms of Assistance: 1992–2003**




*Note: Provisional data for 2003.*
Source: Council for the Development of Cambodia

ក្នុងចំណោមដៃគូអភិវឌ្ឍន៍បរទេសចំបងៗ អ្នកផ្តល់ជំនួយទ្វេភាគីបានបើកផ្តល់ ២ពាន់លានដុល្លារនៅឆ្នាំ១៩៩២-២០០៣ ឬ ៣៨%នៃការបើកផ្តល់សរុប ហើយ ជប៉ុន សហរដ្ឋអាមេរិក និង អូស្ត្រាលី គឺជាអ្នកផ្តល់ជំនួយចំបងគេ ។ ស្ថាប័នពហុភាគីដែលមានបណ្តាទីភ្នាក់ងាររបស់ UN និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ បានផ្តល់ ១,៤៤ពាន់លានដុល្លារ ឯសហភាពអឺរ៉ុប បានផ្តល់ ១,៣៦ ពាន់លានដុល្លារក្នុងរយៈពេលនេះ ។

Among major external development partners, bilateral donors disbursed about $2 billion during 1992–2003, 38 percent of total disbursements, among which Japan, the US and Australia were the top three donors. Multilateral agencies, which consist of United Nations agencies and international financial institutions, provided $1.44 billion during this period, while the European Union provided $1.36 billion.

**External Development Assistance Disbursements by Major Donors: 1992-2003**




*Note: Provisional data for 2003.*
Source: Council for the Development of Cambodia

# ការអនុវត្តន៍ថវិកាជាតិ
# National Budget Operations

នៅខែតុលា ២០០៤ អតិរេកថវិកាចរន្តរបស់កម្ពុជាមាន ១៩,៨ពាន់លានរៀល ឬ ១៦,៩ពាន់លានរៀលច្រើនជាងខែមុន ។ ពីខែមករា ដល់ តុលា ២០០៤ ប្រតិបត្តិការថវិកាចរន្តមានអតិរេក ៦១៥ពាន់លានរៀល ធៀបនឹង ១៥៤,៦ពាន់លានរៀលកាលពីខែមករា-តុលា ២០០៣ ។

In October 2004, Cambodia's current budget surplus was 19.8 billion riels, 16.9 billion riels more than in the preceding month. From January to October 2004, current budget operations exhibited a surplus of 615 billion riels, compared to 154.6 billion riels during January–October 2003.

**Current Budget Operations**
(in billion riels)




*Note: Provisional for January–October 2004.*
Source: Ministry of Economy and Finance

នៅខែតុលា ២០០៤ ចំណូលថវិកាចរន្តកម្ពុជាមាន ១២៦,៤ពាន់លានរៀល គឺបានរួមចុះ ៨,៦%តូចជាងខែមុន។ ប៉ុន្តែក្នុង ១១ខែដើមឆ្នាំ២០០៤ វាបាន កើនឡើង ១៨% ដល់ ១.៥៧៦ពាន់លានរៀល ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០០៣ ដោយសារចំនូលពន្ធដែលកើន ២៥% ដល់ ១.២០០ពាន់លាន។ ចំណូលពន្ធក្នុងស្រុកលើទំនិញនិងសេវា កើន ៣៥% ដល់ ៦៨៧,៣ពាន់លានរៀល, ពន្ធលើពាណិជ្ជកម្មក្រៅប្រទេសកើន ១៨% ដល់ ៣៧៨ពាន់លានរៀល និងពន្ធលើប្រាក់ចំនូលកើន ១៥% ដល់ ១៣១.៥ពាន់លានរៀល។

In October, Cambodia's current budget revenues amounted to 126.4 billion riels, a contraction of 8.6 percent from the preceding month. However, current revenues increased by 18 percent, to 1,576 billion riels, in the first 11 months of 2004, compared to the same period of 2003. This reflected a rise in tax revenues (by 25 percent to 1,200 billion riels). Collections from domestic taxes on goods and services rose by 35 percent to 687.3 billion riels, taxes on international trade by 18 percent to 378 billion riels and income tax by 15 percent to 131.5 billion riels.

**Current Budget Revenue**
(billion riels)




*Note: Provisional for January-October 2004.*
Source: Ministry of Economy and Finance

នៅខែតុលា ចំណាយថវិកាចរន្តកម្ពុជា ចុះដល់ ១០៦,៦ពាន់លានរៀល ឬ ២១% ទាបជាងខែកញ្ញា ។ ក្នុង ១១ខែដើមឆ្នាំ២០០៤ ចំនាយចរន្តមាន សរុប ៩៦១ពាន់លានរៀល (១៨,៥%តិចជាងរយៈពេលដូចគ្នាឆ្នាំមុន) ក្នុងនេះ ចំណាយលើរដ្ឋបាលស៊ីវិល ថយចុះ ២២,៥% ដល់ ៦៧២,២ពាន់លានរៀល, លើការពារជាតិ និងសន្តិសុខ ចុះ ១២,២% ដល់ ២៥២,៤ពាន់លានរៀល ។

Cambodia's current budget expenditures in October declined by 21 percent, to 106.6 billion riels, from September. For the first 11 months of 2004, current expenditures totalled 961 billion riels, 18.5 percent less than in the same period of 2003. Of this, expenditures for civil administration, which consists of central and provincial administrations, fell by 22.5 percent, to 672.2 billion riels, while expenditures for defence and security declined by 12.2 percent, to 252.4 billion riels. Interest payments on loans rose markedly, by 49 percent, to 36.4 billion riels.

**Current Budget Expenditure**
(billion riels)




*Note: Provisional for January-October 2004.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា
# Economic Activity of Selected Economic Partners of Cambodia

នៅខែវិច្ឆិកា ២០០៤ ផលិតកម្មឧស្សាហកម្ម US កើនតាមអត្រាប្រចាំឆ្នាំ ៣,៨% ឬ ១,៤% ទាបជាងខែមុន ។ ក្នុងខែដដែល ផលិតកម្មឧស្សាហកម្មជប៉ុនកើន ៤,៣% ដោយសារជាសំខាន់តំរូវការច្រើនពីក្រៅប្រទេសនូវរថយន្ត និងដែក យោងតាម Bloomberg News ។ ផលិតកម្មឧស្សាហកម្មនៅសហភាពអឺរ៉ុបកើន ១,៥% នៅខែវិច្ឆិកា ។

In November 2004, US industrial production grew at an annualised rate of 3.8 percent, 1.4 percentage points lower than in the previous month. During the same period, industrial production in Japan rose by 4.3 percent, mainly due to a strong overseas demand for cars and steel, according to Bloomberg News. Industrial production in the European Union expanded by 1.5 percent in November.

### Industrial Production in the US, Europe and Japan
(percentage change over the previous year)




*Note: The latest data available are for November 2004.*
Sources: *Economist* (Dec.4–10, 2004)

នៅខែវិច្ឆិកា ២០០៤ ផលិតកម្មឧស្សាហកម្មនៅកូរ៉េខាងត្បូង (សេដ្ឋកិច្ចធំបង្គួរលំដាប់ទី៣ នៅអាស៊ី) កើនតាមអត្រាប្រចាំឆ្នាំ ១០,១% ដោយសារជាសំខាន់កំណើនការនាំចេញរថយន្ត chip កុំព្យូទ័រ និងទូរស័ព្ទចល័ត ។ ថ្វីបើប្រាក់វ៉ុនកូរ៉េខាងត្បូងបន្តឡើងថ្លៃទល់នឹងរូបិយវត្ថុធំៗ ប៉ុន្តែការនាំចេញនឹងនៅតែលូតលាស់យឺតៗក្នុងឆ្នាំខាងមុខ ។ ផលិតកម្មឧស្សាហកម្មចិន បន្ថយកំណើនមកត្រឹម ១៤,៨%នៅខែវិច្ឆិកា ២០០៤ ។

In November, industrial output in South Korea—Asia’s third largest economy—rose at an annual rate of 10.1 percent, largely reflecting an increase in exports of cars, computer chips and cell phones, according to Bloomberg News. But if the South Korea won continues to gain value against major currencies, exports will grow slowly in the coming year. Industrial production growth in China continued to slow, to 14.8 percent in November 2004.

### Industrial Production in China and South Korea
(percentage change over the previous year)




*Note: The latest data available are for November 2004.*
Source: *Economist* (Dec. 4-10, 2004)

នៅខែវិច្ឆិកា ២០០៤ ផលិតកម្មឧស្សាហកម្មសិង្ហបុរីស្ទុះឡើង ១៣,២% ខ្ពស់ជាងកាលពី១ឆ្នាំមុន និង ១០,៨%លឿនជាងកាលពីខែមុន ។ នៅខែធ្នូ វាកើនថែមទៀតដល់ ៣១,៧% ដោយសារផលិតផលខាងឱសថ រីកធំ ៥ដងជាងកាលពី១ឆ្នាំមុន ។ ក្នុងរយៈពេលដដែល ផលិតកម្មឧស្សាហកម្មនៅថៃ និងម៉ាឡេស៊ី កើនលឿនជាងដល់ ៩,៥% និង ៩,៩% រៀងៗគ្នា ។

In November, industrial production in Singapore surged by 13.2 percent from a year ago, 10.8 percentage points faster than in the previous month. Singapore's industrial output rose further, by 31.7 percent in December, as pharmaceutical output expanded more than five times over a year earlier, according to Bloomberg News. During the same period, industrial production in Thailand and Malaysia grew at faster rates of 9.5 percent and 9.9 percent, respectively.

### Industrial Production in Some ASEAN Countries
(percentage change over previous year)




*Note: The latest data available for Thailand and Malaysia are for November 2004.*
Source: *Economist* (Dec. 4–10, 2004)

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា
# Inflation Rates in Selected Economic Partners of Cambodia

នៅខែវិច្ឆិកា ២០០៤ ថ្លៃទំនិញប្រើប្រាស់ជប៉ុនកើន ០,៨% ខ្ពស់ជាងកាលពី ១ឆ្នាំមុន ។ ធនាគារកណ្តាលជប៉ុន បន្តរក្សាអត្រាការប្រាក់កំចីអន្តរ-ធនាគារ នៅត្រឹម ០,០០១% រហូតដល់សំពាធបរិត្តផរណាបានធូរស្រាល ។ ក្នុងខែនេះដែរ ថ្លៃទំនិញប្រើប្រាស់នៅ US កើនតាមអត្រាប្រចាំឆ្នាំ ៣,៥% ហើយនៅ EU វាកើន ២,២% ខ្ពស់ជាងឆ្នាំមុន ។

In November 2004, consumer prices in Japan rose by 0.8 percent from a year earlier. The Bank of Japan continues to keep its inter-bank overnight loan rate (an equivalent of the US Federal Reserve's funds rate) at 0.001 percent until deflation pressures ease for at least a few months. During the same period, consumer prices in the US rose at an annual rate of 3.5 percent, while in the EU they rose 2.2 percent above the previous year.

## Inflation Rates in the US, Europe and Japan
(percentage change over previous year)




*Note: The latest data available are for Nov 2004.*
Sources: IMF and *Economist* (Jan. 15-21, 2005)

នៅខែវិច្ឆិកា ២០០៤ ថ្លៃទំនិញប្រើប្រាស់នៅចិន មានកំរិត ២,៨%ខ្ពស់ជាងខែវិច្ឆិកា ២០០៣ ប៉ុន្តែត្រូវជា ១,៥%ទាបជាងនៅខែតុលា ។ ដើម្បីទប់អតិផរណាថែមទៀត ធនាគារកណ្តាលចិន គ្រោងកាត់បន្ថយកំណើនការផ្គត់ផ្គង់សាច់ប្រាក់ពីកំរិត ១៧% ដែលកំណត់ក្នុងផែនការនៅខែមករា ២០០៤ មកត្រឹម ១៥% នៅឆ្នាំនេះ ។ ថ្លៃទំនិញប្រើប្រាស់នៅកូរ៉េខាងត្បូង និងហុងកុង កើនតាមអត្រាប្រចាំឆ្នាំ ៣,៣% និង ០,២% រៀងៗគ្នា ។

In November, consumer prices in China were 2.8 percent higher than in November 2003, but 1.5 percentage points lower than in October. To curb the inflation rate further, the Bank of China plans to cut money supply growth from the 17 percent target set in January 2004 to 15 percent this year, according to Bloomberg News released on 5 January. Prices in South Korea and Hong Kong in November rose at annual rates of 3.3 percent and 0.2 percent, respectively.

## Inflation Rates in China, Hong Kong and South Korea
(percentage change over previous year)




*Note: The latest data available are for November 2004.*
Sources: IMF and *Economist* (Jan. 15–21, 2005)

នៅខែវិច្ឆិកា ២០០៤ ថ្លៃទំនិញប្រើប្រាស់នៅម៉ាឡេស៊ី កើន ២,២% ខ្ពស់ជាងកាលពី ១ឆ្នាំមុន (កំរិតខ្ពស់បំផុតក្នុងរយៈ៥ឆ្នាំ) និងប្រហែលនៅត្រឹម ២,១% នៅខែធ្នូ ដោយសារជាសំខាន់កំណើនថ្លៃប្រេងឥន្ធនៈ និងចំនាយប្រើប្រាស់ ដែលធ្វើឱ្យឡើងថ្លៃម្ហូបអាហារ និងដឹកជញ្ជូន ។ ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរីកើន ១,៧%ខ្ពស់ជាងខែមុន ឯនៅថៃ អតិផរណាថយចុះ ៣%នៅខែវិច្ឆិកា ។

In November, consumer prices in Malaysia rose 2.2 percent above a year earlier, a five-year inflation high, and are likely to hold at 2.1 percent in December, mainly due to higher fuel prices and consumer spending that raised food and transportation costs, according to Bloomberg News. Consumer prices in Singapore rose by 1.7 percent from the previous year, while in Thailand the inflation rate fell to 3 percent in November.

## Inflation Rate in Selected ASEAN Countries
(percentage change over the previous year)




*Note: The latest data available for Singapore and Thailand are for November 2004.*
Sources: IMF and *Economist* (Jan. 15–21, 2005)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែមករា ដុល្លារUS បន្តចុះថ្លៃទល់នឹងយ៉េនដល់ ១០៣,៣យ៉េន/ដុល្លារ ។ ប៉ុន្តែដុល្លារUSឡើងថ្លៃ ០,៦៧% ទល់នឹងអឺរ៉ូ ដល់ ០,៧៦អឺរ៉ូ/ដុល្លារ ។ ក្នុង ៣ឆ្នាំកន្លងមក ដុល្លារUSចុះថ្លៃ ៣៥%ទល់នឹងអឺរ៉ូ និង២៥%ទល់នឹងយ៉េន ។ បើសិនអតិរេកថវិការបស់ US នៅតែបន្តកើនឡើង ដុល្លារនឹងចុះខ្សោយថែមទៀតនៅឆ្នាំ២០០៥ ។ ការចុះថ្លៃប្រាក់ដុល្លារ បានប៉ះពាល់ដល់អ្នកនាំចេញនៅអឺរ៉ុប និងអាស៊ីដែលធ្វើការនាំចេញទៅ US ។

In January, the US dollar continued to depreciate against the Japanese yen, to 103.3 yen. In contrast, the dollar strengthened slightly, by 0.67 percent, to 0.76 euros. The dollar has lost about 35 percent of its value against the euro and 25 percent against the yen over the past three years. If the US deficit continues to grow, the dollar will weaken further in 2005. The falling dollar has hurt European and Asian exporters to the US.

**Euro and Japanese Yen against US Dollar**




*Note: Data are to 24 January 2005.*
Source: Federal Reserve Bank of New York

នៅខែមករា ដុល្លារហុងកុងប្តូរបាន ៧,៧៩ដុល្លារហុងកុង/ដុល្លារUS គឺជិតស្មើអត្រាកំណត់របស់ខ្លួនត្រឹម ៧,៨០ដុល្លារហុងកុង/ដុល្លារUS ។ អាជ្ញាធររូបិយវត្ថុហុងកុងបានបង្ហើបថា ហុងកុង នឹងបន្តរក្សាស្ថិរភាពរូបិយវត្ថុខ្លួនទោះបី ចិនកែប្រែនយោបាយអត្រាប្តូរប្រាក់យ៉ាងដូចម្តេចក្តី ។ ក្នុងខែនេះដែរ ប្រាក់វ៉ុនកូរ៉េខាងត្បូងបន្តឡើងថ្លៃដល់ ១.០៤១,២វ៉ុន/ដុល្លារUS ធៀបនឹង ១.០៥០,៣វ៉ុន/ដុល្លារUS កាលពីខែធ្នូ ។

In January, the Hong Kong dollar traded at 7.79 to the US dollar, close to its peg rate of 7.80. The Hong Kong Monetary Authority reveals that Hong Kong will maintain currency stability regardless of any changes in China's exchange rate policy (Hong Kong is the biggest Chinese export market). At the same time, the South Korean won continued to appreciate, to 1,041.2 won to the US dollar, from 1,050.3 won in December.

**South Korean Won and Hong Kong Dollar against US Dollar**




*Note: Data are to 24 January 2005.*
Source: Federal Reserve Bank of New York

នៅខែមករា ប្រាក់បាតថៃ បន្តឡើងថ្លៃទល់នឹងដុល្លារUS ដល់ ៣៨,៨បាត / ដុល្លារUS ។ យោងតាម Dow Jones កំលាំងប្រាក់បាតឆ្លុះបញ្ចាំងជាសំខាន់ពីការចុះខ្សោយប្រាក់ដុល្លារ និងលំហូរមូលធនយ៉ាងច្រើនចូលប្រទេសថៃ ។ ក្នុងខែដដែល ដុល្លារសិង្ហបុរីឡើងថ្លៃបន្តិចបាន ០,២% ដល់ ១,៦៣ដុល្លារសិង្ហបុរី/ដុល្លារUS ។

In January, the Thai baht continued to gain value against the US dollar, reaching 38.8 baht, mostly a four-year high. According to Dow Jones, the baht's strength largely reflects the dollar's weakness and strong capital flows into Thailand. During the same period, the Singapore dollar appreciated slightly, by 0.2 percent, to 1.63 to the US dollar.

**Thai Baht and Singaporean Dollar against US Dollar**




*Note: Data are to 24 January 2005.*
Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ
# Commodity Prices in World Markets

ថ្វីបើនៅឆ្នាំប្រមូលផល២០០៤-០៥ ផលិតកម្មអង្ករក្នុងពិភពលោកឡើងដល់ ៣៩៧.៣៥៣.០០០តោនក្តី (កំរិតខ្ពស់បំផុតក្នុងរយះ ៣ឆ្នាំ), ថ្លៃអង្ករនៅទីផ្សារអន្តរជាតិក្រុងបាងកក រំពឹងថាឡើងដល់ ២៣០ដុល្លារ/តោននៅឆ្នាំ២០០៤ ឬកំណើន ៣៣% ធៀបនឹងឆ្នាំ២០០១ ។ ផលិតកម្មអង្ករថៃមាន ១៧.៩០០.០០០តោននៅឆ្នាំ២០០៤-០៥ ក្នុងនេះ ៩.០០០.០០០តោន បាននាំចេញ ។

Although world rice production in the 2004/5 crop year reached 397,353,000 tonnes, the highest level in the past three years, rice prices in the Bangkok international market are forecast to climb to $230/tonne in 2004, an increase of 33 percent from 2001, according to the World Bank. Thailand's rice production amounted to 17,900,000 tonnes in 2004/05, of which 9,000,000 tonnes were exported.

### Rice Prices and Production
In Thailand (US$/tonne)




*Note: Data for 2004 are estimated by World Bank.*
Source: World Bank

ថៃមិនគ្រាន់តែជាប្រទេសផលិតកៅស៊ូធម្មជាតិធំជាងគេនោះទេ ប៉ុន្តែក៏នាំមុខគេដែរក្នុងការនាំចេញកៅស៊ូ គឺបាននាំចេញ ២.៥៩៣.០០០តោននៅឆ្នាំ២០០៣ ហើយប្រទេសនាំចេញធំបំផុតលំដាប់ទី២ គឺឥណ្ឌូនេស៊ី ។ ដោយសារតំរូវការកង់រថយន្តច្រើន ចិនបានក្លាយជាអ្នកប្រើកៅស៊ូធម្មជាតិច្រើនជាងគេតាំងពីឆ្នាំ២០០១ មក ហើយនៅឆ្នាំ២០០៣ តំណាងឱ្យ ១៨,៧% នៃការប្រើប្រាស់ក្នុងពិភពលោក ។

Thailand is not only the largest natural rubber producing country but also the leading rubber exporter. Thailand's natural rubber net exports amounted to 2,593,000 tonnes in 2003, the highest volume in the past four years. The second largest natural rubber net exporter is Indonesia. Due to a large demand for car tires, China has become the largest user of natural rubber since 2001. In 2003, China's natural rubber consumption accounted for 18.7 percent of world consumption.

### Natural Rubber Net Exporting Countries




Source: World Bank

នៅខែមករា ទាំងប្រេងឆៅ និងប្រេងសាំងបានឡើងថ្លៃ គឺរហូតដល់ ៣៦,៩២ដុល្លារ/ធុង និង ៣២,៤សេន/លីត្រ ធៀបនឹង៣៤,៣៩ដុល្លារ/ធុង និង ២៧,៣សេន/លីត្រ នៅខែធ្នូ ។ តាំងពីដើមឆ្នាំ២០០៤ មក ថ្លៃប្រេងឆៅនៅតែខ្ពស់ជាងកំរិតថ្លៃគោលដៅ ២២-២៨ដុល្លារ/ធុង ដែលកំណត់ដោយ OPEC កាលពីខែមីនា ឆ្នាំ២០០០ ។ ប៉ុន្តែ OPEC បានសំរេចរក្សាកំរិតអតិបរមានៃផលិតកម្មរបស់ខ្លួននៅត្រឹម ២៧លានធុង/ថ្ងៃ ។

In January, both crude oil and gasoline prices rose, respectively to $36.92/barrel and 32.4 cents/litre, from $34.39 and 27.3 cents/litre in December. Since early 2004, the crude oil price has remained higher than the Organisation of Petroleum Exporting Countries' (OPEC) target band of $22–28 a barrel, set in March 2000. Nevertheless, OPEC has decided to keep its production ceiling at 27 million barrels a day, according to Reuters.

### Prices of Crude Oil and Gasoline




***Note: Data are to 25 January 2005.***
Sources: EIA and IEA